អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

លិខិតថ្វាយព្រះពរ

សូមក្រាបបង្គំទូលថ្វាយ
ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈ

ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ឆ្នាំមមែ សប្តស័ក ព.ស. ២៥៥៩ គ.ស. ២០១៥ ទូលព្រះបង្គំជាខ្ញុំ ភរិយា បុត្រា បុត្រី ព្រមទាំងថ្នាក់ដឹកនាំ និង មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ក្រោមឱវាទនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សូមរាជានុញ្ញាតក្រាបបង្គំទូលថ្វាយនូវសព្ទសាធុការបវរសួស្តីមហាប្រសើរ ថ្វាយចំពោះព្រះករុណាជាអម្ចាស់ជីវិតមិ្លឈើត្បូង សូមទ្រង់មានព្រះជន្មាយុយឺនយូរ ព្រះរាជសុខភាពបរិបូណ៌ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណភ្លឺថ្លា ដើម្បីគង់ជាម្លប់ដ៏ត្រជាក់ដល់ប្រជារាស្ត្រ ជាកូនចៅព្រះអង្គ និង ដើម្បីទ្រង់ដឹកនាំប្រជាជាតិកម្ពុជា ឆ្ពោះទៅកាន់វឌ្ឍនភាពជានិច្ចនិរន្តរ៍អស់កាលជាយូរអង្វែងតរៀងទៅ ។

ទូលព្រះបង្គំយើងខ្ញុំ ជាកូនចៅព្រះអង្គ សូមព្រះរាជានុញ្ញាតក្រាបបង្គំទូលថ្វាយសារជាថ្មី នូវកត្តញ្ញុតាធម៌ដ៏ខ្ពង់ខ្ពស់បំផុត ចំពោះព្រះមហាករុណាទិគុណដ៏ធំធេង ដែលព្រះករុណាជាអម្ចាស់បានប្រោសប្រទានដល់ប្រជារាស្ត្រ ជាកូនចៅព្រះអង្គ ក្នុងខណៈដែលព្រះអង្គទ្រង់គង់ជានិមិត្តរូបដ៏ប្រសើរខ្ពង់ខ្ពស់បំផុតនៃអធិបតេយ្យភាព និង ឯករាជ្យភាព ព្រមទាំងតាមរយៈព្រះរាជបេសកកម្មទ្រទ្រង់វប្បធម៌ជាតិ និង សកម្មភាពមនុស្សធម៌ដ៏ថ្លៃថ្លាបំផុត ។

គួរពុំគួរសូមទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទោស ។

ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៥

ឧបនាយករដ្ឋមន្ត្រី
ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

អ៊ឹង - ម៉ូលី

អាសយដ្ឋាន ៖ អគារលេខ១៦ ផ្លូវ២៧១កែង១៥០ សង្កាត់ទឹកល្អក់II ខណ្ឌទួលគោក រាជធានីភ្នំពេញ
Tel: (855) 23 885 129 • Fax: (855) 23 885 279 • E-mail: info@naa.org.kh • Website: naa.org.kh

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

លិខិតថ្វាយព្រះពរ

សូមក្រាបបង្គំទូលថ្វាយ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ
ព្រះវររាជមាតាជាតិ ជាទីគោរពសក្ការៈ

ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ឆ្នាំមមែ សប្តស័ក ព.ស. ២៥៥៩ គ.ស. ២០១៥ ទូលព្រះបង្គំជាខ្ញុំ ភរិយា បុត្រា បុត្រី ព្រមទាំងថ្នាក់ដឹកនាំ និង មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ក្រោមឱវាទនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សូមព្រះបរមរាជានុញ្ញាត បួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក សូមថ្វាយសព្ទសាធុការពរបវរសួស្តី សិរីមង្គលមហាប្រសើរចំពោះសម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ដើម្បីទ្រង់មានព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ព្រះរាជសុខភាពបរិបូណ៌ ព្រះរាជកាយពលមាំមួន ព្រះបញ្ញាញាណភ្លឺថ្លា និង គង់ជាម្លប់ដ៏ត្រជាក់ដល់ប្រជារាស្ត្រ ជាកូនចៅ ចៅទួតរបស់ព្រះអង្គជាដរាបអង្វែងទៅ ។

ទូលព្រះបង្គំយើងខ្ញុំ ជាកូនចៅព្រះអង្គ សូមព្រះរាជានុញ្ញាតក្រាបបង្គំទូលថ្វាយសារជាថ្មី នូវកត្តញ្ញុតាធម៌ដ៏ខ្ពង់ខ្ពស់បំផុត ចំពោះព្រះមហាករុណាទិគុណដ៏ធំធេង ដែលសម្តេចព្រះមហាក្សត្រី សម្តេចម៉ែ បានប្រោសប្រទានដល់ប្រជារាស្ត្រ ជាកូនចៅព្រះអង្គ តាមរយៈព្រះរាជបេសកកម្មការពារយ៉ាងរឹងមាំនូវឯករាជ្យភាព អធិបតេយ្យភាព បូរណភាពទឹកដីក្នុងកាលកន្លងមក និង តាមរយៈព្រះរាជសកម្មភាពផ្នែកសង្គមកិច្ច វប្បធម៌ដ៏ថ្លៃថ្នូរបំផុត ។

គួរពុំគួរសូម **សម្តេចព្រះមហាក្សត្រី** ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទោស ៕

ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៥

អនុរដ្ឋមន្ត្រី
ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

អឿង - ម៉ូលី

អាសយដ្ឋាន ៖ អគារលេខ១៦ ផ្លូវ២៧១កែង១៥០ សង្កាត់ទឹកល្អក់ii ខណ្ឌទួលគោក រាជធានីភ្នំពេញ
Tel: (855) 23 885 129 • Fax: (855) 23 885 279 • E-mail: info@naa.org.kh • Website: naa.org.kh

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

លិខិតជូនពរ

សូមគោរពជូន
សម្តេចអគ្គមហាធម្មរាជាធិសាល ជា ស៊ីម
ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

សម្តេចអគ្គមហាធម្មរាជាធិសាលជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត !

ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ឆ្នាំមមែ សប្តស័ក ព.ស. ២៥៥៩ គ.ស. ២០១៥ ខ្ញុំបាទ ភរិយា បុត្រា បុត្រី ថ្នាក់ដឹកនាំ និង មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ក្រោមឱវាទនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានកិត្តិយសសន្តនគ្គុរុគ្គម គោរពជូនពរ ជ័យសិរីមង្គល បវរមហាប្រសើរ ជូនចំពោះសម្តេចអគ្គមហាធម្មរាជាធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា សូមសម្តេច បុត្រា បុត្រី និង ចៅៗជាទីស្រឡាញ់ ជួបប្រទះតែសេចក្តីសុខ សុភមង្គល និង ប្រកបដោយ ពុទ្ធពរទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក និង ទេវតាឆ្នាំថ្មីព្រះនាម **វាក្យសោធនី** ប្រោសប្រទានពរជ័យសិរីមង្គល ជូន **សម្តេចអគ្គមហាធម្មរាជាធិសាល** មានសុខសាធបរិបូណ៌ អាយុយឺងយូរ កម្លាំងខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ ដើម្បី ដឹកនាំព្រឹទ្ធសភា និង កសាងអភិវឌ្ឍន៍មាតុភូមិឱ្យកាន់តែរីកចម្រើនរុងរឿងតរៀងទៅ ។

សូម **សម្តេចអគ្គមហាធម្មរាជាធិសាល** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតពីយើងខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៥

ឯកឧត្តសន្តិបណ្ឌិត
ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

អៀង - មូលី

អាសយដ្ឋាន ៖ អគារលេខ១៦ ផ្លូវ៦៧កែង១៥០ សង្កាត់ទឹកល្អក់II ខណ្ឌទួលគោក រាជធានីភ្នំពេញ
Tel: (855) 23 885 129 • Fax: (855) 23 885 279 • E-mail: info@naa.org.kh • Website: naa.org.kh

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

លិខិតជូនពរ

សូមគោរពជូន

ឯកឧត្តម សាយ ឈុំ

ប្រធានស្តីទី ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

ឯកឧត្តមជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត !

ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ឆ្នាំមមែ សប្តស័ក ព.ស. ២៥៥៩ គ.ស. ២០១៥ ខ្ញុំបាទ ភរិយា បុត្រា បុត្រី ថ្នាក់ដឹកនាំ និង មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ក្រោមឱវាទនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានកិត្តិយសសន្តនឧត្តុង្គឧត្តម គោរពជូនពរ ជ័យសិរីមង្គល បវរមហាប្រសើរ ជូនចំពោះឯកឧត្តម **សាយ ឈុំ** ប្រធានស្តីទី ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា សូម ឯកឧត្តម បុត្រា បុត្រី និង ចៅៗជាទីស្រឡាញ់ ជួបប្រទះតែសេចក្តីសុខ សុភមង្គល និង ប្រកបដោយពុទ្ធពរទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក និង ទេវតាឆ្នាំថ្មីព្រះនាម **វាក្យសារទេវី** ប្រោសប្រទានពរជ័យសិរីមង្គល ជូន **ឯកឧត្តម** មានសុខសាធបរិបូណ៌ អាយុយឺនយូរ កម្លាំងខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ ដើម្បីដឹកនាំព្រឹទ្ធសភា និង កសាង អភិវឌ្ឍន៍មាតុភូមិឱ្យកាន់តែរីកចម្រើនរុងរឿងតរៀងទៅ ។

សូម **ឯកឧត្តម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតពីយើងខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៥

ឧទ្ទេសរដ្ឋមន្ត្រី

ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

អ៊ឹង - ម៉ូលី

អាសយដ្ឋាន ៖ អគារលេខ១៦ ផ្លូវ៦៧១កែង១៥០ សង្កាត់ទឹកល្អក់ii ខណ្ឌទួលគោក រាជធានីភ្នំពេញ
Tel: (855) 23 885 129 • Fax: (855) 23 885 279 • E-mail: info@naa.org.kh • Website: naa.org.kh

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

លិខិតជូនពរ

សូមគោរពជូន
សម្តេចអគ្គមហាពញ្ញាចក្រី ហេង សំរិន
ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

សម្តេចអគ្គមហាពញ្ញាចក្រីជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត !

ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ឆ្នាំមមែ សប្តស័ក ព.ស. ២៥៥៩ គ.ស. ២០១៥ ខ្ញុំបាទ ករិយា បុត្រា បុត្រី ថ្នាក់ដឹកនាំ និង មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ក្រោមឱវាទនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានកិត្តិយសដ៏ឧត្តុង្គឧត្តម គោរពជូនពរជ័យសិរីមង្គល បវរមហាប្រសើរ ជូនចំពោះសម្តេចអគ្គមហាពញ្ញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា សូមសម្តេច ឧកញ៉ាជាទីស្រឡាញ់ ជួបប្រទះតែសេចក្តីសុខ សុភមង្គល និង ប្រកបដោយពុទ្ធពរទាំង ៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក និង ទេវតាឆ្នាំថ្មីព្រះនាម **វាក្យសាធនី** ប្រោសប្រទានពរជ័យសិរីមង្គលជូន **សម្តេចអគ្គមហាពញ្ញាចក្រី** មានសុខភាពបរិបូណ៌ អាយុយឺនយូរ កម្លាំងខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ ដើម្បីដឹកនាំរដ្ឋសភា និង កសាងអភិវឌ្ឍន៍មាតុភូមិឱ្យកាន់តែរីកចម្រើនរុងរឿងតរៀងទៅ ។

សូម **សម្តេចអគ្គមហាពញ្ញាចក្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតពីយើងខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៥
ទេសរដ្ឋមន្ត្រី
ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

អ៊ឹង - មូលី

អាសយដ្ឋាន ៖ អគារលេខ១៦ ផ្លូវ៧១កែង១៥០ សង្កាត់ទឹកល្អក់ពី ខណ្ឌទួលគោក រាជធានីភ្នំពេញ
Tel: (855) 23 885 129 • Fax: (855) 23 885 279 • E-mail: info@naa.org.kh • Website: naa.org.kh

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

លិខិតជូនពរ

សូមគោរពជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

សម្តេចអគ្គមហាសេនាបតីតេជោជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត !

ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ឆ្នាំមមែ សប្តស័ក ព.ស. ២៥៥៩ គ.ស. ២០១៥ ខ្ញុំបាទ ភរិយា បុត្រា បុត្រី ថ្នាក់ដឹកនាំ និង មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ក្រោមឱវាទនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានកិត្តិយសដ៏ឧត្តុង្គឧត្តម គោរពជូនពរជ័យសិរីមង្គលបវរមហាប្រសើរ ជូនចំពោះសម្តេចអគ្គមហាសេនាតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** បុត្រា បុត្រី និង ចៅៗជាទីស្រឡាញ់ សូមជូនប្រទេះតែសេចក្តីសុខ សុភមង្គល និង ប្រកបដោយពុទ្ធពរទាំង ៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមបួងសួងអស់វត្ថុស័ក្តិសិទ្ធិក្នុងឆាក និង ទេវតាឆ្នាំថ្មីព្រះនាម **វាក្យសាធេវី** ប្រោសប្រទានពរជ័យសិរីមង្គលជូន **សម្តេចអគ្គមហាសេនាបតីតេជោ** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** បុត្រា បុត្រី និង ចៅៗជាទីស្រឡាញ់ មានសុខភាពបរិបូណ៌ អាយុយឺនយូរ កម្លាំងខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ ដើម្បីដឹកនាំកសាង និង អភិវឌ្ឍន៍មាតុភូមិឱ្យកាន់តែរីកចម្រើនរុងរឿងថែមទៀតរៀងទៅ ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ** នាយករដ្ឋមន្ត្រី មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតពីយើងខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៥

ទេសរដ្ឋមន្ត្រី
ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

អ៊ឹង - ម៉ូលី

អាសយដ្ឋាន ៖ អគារលេខ១៦ ផ្លូវ៦៧កែង១៩០ សង្កាត់ទឹកល្អក់II ខណ្ឌទួលគោក រាជធានីភ្នំពេញ
Tel: (855) 23 885 129 • Fax: (855) 23 885 279 • E-mail: info@naa.org.kh • Website: naa.org.kh